ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា

ប្រចាំប្រទេសជប៉ុន

តូក្យូ ថ្ងៃទី២០ខែ មករា ឆ្នាំ ២០១២

លេខ ០២៥/១២-ឯក

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**<u>កម្មវត្ថុ</u>:** របាយការណ៍នៃកិច្ចប្រជុំ EB របស់ AJC ។

ខ្ញុំមានកិត្តិយសសូមជំរាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំASEAN-Japan Centre's Executive Board (EB) នាថ្ងៃទី **១៣ មករា ២០១២** Japan's EB បានជូនព័ត៌មានថា **the Extension of the Agreement Establishing the AJC នឹងជួបការលំបាក** ដោយមានការរិះគន់យ៉ាងខ្លាំងពីសំណាក់អ្នកតំណាងរាស្ត្រមួយចំនួន លើសកម្មភាព ក៏ដូចការចំណាយថវិកាខ្ជះខ្ជាយកន្លងមក របស់ AJC ដោយបង្កប់ន័យថា "**តើ AJC នៅមានសារៈសំខាន់ទៀតទេ នៅពេលបច្ចុប្បន្ននេះ?**"

ម្យ៉ាងទៀត ដោយ**ជប៉ុន** ជួបនូវកង្វះថវិកា ជារៀងរាល់ឆ្នាំ និងដោយសង្កេតឃើញថា **ប្រទេសអាស៊ានមួយចំនួន** មានសេដ្ឋកិច្ចវិវឌ្ឍន៍រីកចំរើន ចាប់តាំងពីAJC បានបង្កើតឡើងនៅឆ្នាំ ១៩៨១ ហើយនោះ ហេតុនេះ ភាគី**ជប៉ុន** **ចាំបាច់លើកគំរោងកែទម្រង់ ទាំង**Activities **ទាំង**Organizational restructuring **របស់**AJC ដូចខាងក្រោម ដើម្បីជានិរន្តរភាពនៃដំណើរការរបស់ AJC ទៅថ្ងៃមុខទៀត:

**1 - *<u>Selection and Concentration of Activities</u>*:**

- *Japan proposes to streamline the Centre activities. Currently, Indonesia, Malaysia, Philippines, Singapore, Thailand and Vietnam operate wholly or partly own government offices for trade, investment and tourism in Japan. The Centre should not implement the projects which could duplicate with the activities by the above mentioned offices. As a result, the Centre activities will be more focused on such ASEAN countries as CLMV.*
- *However, if it is foresaw that the coordination between the Centre and a government office would remarkably improve the productivity of some activities, the Centre can implement them. Moreover, the Centre can continue activities involving all ASEAN Member Countries, such as "ASEAN Fair" and "ASEAN interior lifestyle". Therefore, the name of the ASEAN-Japan Centre remains the same.*

**2 - *<u>Organizational Restructuring</u>*:**

- *Japan proposes to merge Trade Division and Investment Division into one division. This will improve the coordination between trade and investment operation and increase the productivity of the Centre.*

*8-6-9 AKASAKA, MINATO-KU, TOKYO 107-0052*

*Tel: (81 3)5412-8521 Fax: (81 3)5412-8526*

*E-mail : camembassyjp@gmail.com*

➢ *Based on this organizational restructuring, Japan also proposes;*

- *To reduce number of personnel by approximately 10% (three Japanese staff) within three years.*
- *To degrade the head of Planning and Coordination Division from director to assistant director and to be selected by open recruitment among ASEAN nationalities not by secondment from Japanese foreign ministry.*
- *To degrade one director post in Trade Division to assistant director in newly established Trade and Investment Division.*

ដោយឡែក ពាក់ព័ន្ធទៅនឹងការពន្យាសុពលភាពកិច្ចព្រមព្រៀង ស្តីពីការបង្កើត AJC រយៈពេល **៥ ឆ្នាំ** បន្តទៀត និងការបន្តអាណត្តិទី ២ របស់លោក Yushikuni Ohnishi ជា AJC's Secretary General **ត្រូវបានប្រទេសអាស៊ានទាំង ១០ យល់ព្រមឯកភាព អស់ហើយ** ។

ចំណែកភាគី**ជប៉ុន** **ពុំទាន់មានជំហរផ្លូវការលើបញ្ហាទាំង ២ នេះ នៅឡើយទេ** ដោយរង់ចាំការឯកភាពពី**អាស៊ានទាំង ១០** លើសំណើកំណែទម្រង់របស់**ជប៉ុន** នេះ សិន ។ **ជប៉ុន** នឹងជំរាបពីផែនការលំអិតរបស់ខ្លួន នៅកិច្ចប្រជុំ EB នាថ្ងៃទី **០៧ កុម្ភៈ** បន្ទាប់ពីបានដឹងពី**ជំហររបស់បណ្តាប្រទេសអាស៊ាន និមួយៗ** ហើយ **នឹងផ្តល់ជំហរផ្លូវការ** នៅក្នុងកិច្ចប្រជុំ CD លើកទី **៣១** នាថ្ងៃទី **១៥-១៦ មីនា** ខាងមុខនេះ ។

ទន្ទឹមនេះ សូមបញ្ជាក់ជូនផងដែរថា **ប្រទេសអាស៊ានចាស់ទាំង ៦** មានជំហរចង្អៀតចង្អល់យ៉ាងខ្លាំង ដោយ Proposal របស់ **ជប៉ុន** នេះ:

- ផ្តល់អាទិភាពដល់ CLMV និង
- នៅរក្សាទុកឈ្មោះ "AJC" ដើម្បីបន្តសកម្មភាពដដែល ។

**មតិ:** ដោយម្យ៉ាង AJC's budget ភាគច្រើនជា Contribution របស់**ជប៉ុន** និងម្យ៉ាងទៀត ដោយ Proposed reform នេះ ផ្តល់អត្ថផលច្រើនដល់**កម្ពុជា** ហេតុនេះ ខ្ញុំបាទយល់ឃើញថា **កម្ពុជា គួរគាំទ្រសំណើធ្វើកំណែទម្រង់របស់ ជប៉ុន** ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាព័ត៌មាន និងទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

**ឯកអគ្គរាជទូត**

**ហោ មុនីរ័ត្ន**